**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន**
លេខៈ..៣៨៦ស.៥៤..អ.ជ.ព.ដ

# សេចក្តីថ្លែងការណ៍
## របស់គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមប្រកាសទាត់ចោលទាំងស្រុងនូវសេចក្តីថ្លែងការណ៍ នាថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ របស់ក្រុមឧទ្ទាមក្រៅច្បាប់ ដែលបានចោទប្រកាន់ បំផ្លើស មួលបង្កាច់អំពីសមិទ្ធផលការងារដែលសម្រេចបានដោយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន នៃរាជរដ្ឋាភិបាលកម្ពុជា ហើយបែរជាត្រូវបានពួកក្រុមឧទ្ទាមចោទ ថា "...**ផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ ត្រូវបានគូសដោយវៀតណាម...ការយកផែនទីថ្មីស្រឡាង ខ្នាត ១/២៥ ០០០ ពីវៀតណាម ប្រៀបដូចជាការទទួលយកប្លង់ដីថ្មីនៃប្រទេសកម្ពុជាគូសដោយវៀតណាម ក្នុងន័យថា បូរណភាពទឹកដីកម្ពុជាត្រូវបានកំណត់ដោយវៀតណាម**" ទៅវិញ។

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមប្រកាសបដិសេធចោលទាំងស្រុងនូវការចោទប្រកាន់ ដោយគ្មានមូលដ្ឋានរបស់ក្រុមឧទ្ទាមក្រៅច្បាប់ និងគូកន ដែលមានចេតនាបង្កើត ប្រឌិតរឿង និងផ្សព្វផ្សាយនូវព័ត៌មានមិនពិត ក្នុងចេតនាទុច្ចរិត និងក្នុងគោលបំណងបំភ័ន្តសាធារណមតិជាតិ និងអន្តរជាតិ ឱ្យមានការយល់ច្រឡំមកលើការងារព្រំដែនរបស់រាជរដ្ឋាភិបាលអំពីការធ្វើឲ្យបាត់បង់ទឹកដី ក៏ដូចជាការបណ្តោយឲ្យមានការរំលោភបំពានទឹកដីពីប្រទេសវៀតណាម។

ពាក់ព័ន្ធនឹងការផ្សព្វផ្សាយ ចែកចាយព័ត៌មានក្លែងក្លាយ បំផ្លើសការពិតដោយក្រុមឧទ្ទាមក្រៅច្បាប់ **គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមធ្វើការបដិសេធចោលទាំងស្រុងនូវព័ត៌មានក្លែងបន្លំ និងបំភ្លៃ**ការពិតទាំងនេះ** ដោយហេតុថា៖

១-ការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជាការងារបច្ចេកទេសកំរិតខ្ពស់ អនុវត្តដោយក្រុមជំនាញនៃប្រទេសទាំងពីរ ដោយយកគោលការណ៍ខ្សែព្រំដែនមិនកែប្រែ តាមផែនទីផ្លូវការ បោន ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ស្របតាមមាត្រា២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលជានាបាន

នូវបូរណភាពទឹកដីកម្ពុជា មិនឲ្យបាត់បង់ទឹកដីទៅប្រទេសវៀតណាម ដូចការចោទប្រកាន់ក្នុងសេចក្តីថ្លែងការណ៍របស់ក្រុមឧទ្ទាមក្រៅច្បាប់ និងគូកនឡើយ។

២-ខ្សែព្រំដែនដែលមាននៅលើផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ **ត្រឹមត្រូវតាមខ្សែព្រំដែនដូចមាននៅលើផែនទីបោន ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន** លើកលែងតែតំបន់មួយចំនួនដែលពលរដ្ឋនៃប្រទេសទាំងពីរ កម្ពុជា-វៀតណាម បាននិងកំពុងរស់នៅជាំជុះ អាស្រ័យផលមិនស្របតាមខ្សែព្រំដែនផែនទីបោន ខ្នាត ១/១០០ ០០០ តែប៉ុណ្ណោះ។ ម៉្យាងវិញទៀត ដើម្បីរក្សាទុកដីទាំងនោះជូនពលរដ្ឋខាងលើ រដ្ឋាភិបាលនៃប្រទេសទាំងពីរ កម្ពុជា និងវៀតណាម បានព្រមព្រៀងគ្នារក្សាទុកដីទាំងនោះជូនពលរដ្ឋឲ្យបន្តរស់នៅ និងកាន់កាប់ជាបន្តទៀត **ដោយយកគោលការណ៍ដោះដូរដី មួយស្មើមួយ** ឈរលើស្មារតីគោរពផលប្រយោជន៍គ្នាទៅវិញទៅមក និងសុខដុមរមនារបស់ពលរដ្ឋនៅតំបន់ព្រំដែននៃប្រទេសទាំងពីរ។

៣-ផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ ត្រូវបាន**ធ្វើឡើងដោយកម្ពុជា និងវៀតណាម** ហើយដែលត្រូវបានគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកនៃប្រទេសទាំងពីរ កម្ពុជា និងវៀតណាម **ប្រគល់ឲ្យប្រទេសទី៣ ជាអ្នកបោះពុម្ព** គឺក្រុមហ៊ុន BLOMINFO A/S នៃប្រទេសដាណឺម៉ាក បន្ទាប់ពីការប្រកាសដេញថ្លៃជាអន្តរជាតិ តាមកិច្ចព្រមព្រៀងចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ដែលក្រោយមកត្រូវបានផ្ទេរបន្តទៅឲ្យក្រុមហ៊ុន NIRAS Mapping A/S ប្រទេសដាណឺម៉ាក ដូចមាននៅក្នុងលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣។

៤-ផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ **ជាផែនទីបង្ហាញពីលទ្ធផលប្រមាណជា ៨៤% ដែលកម្ពុជា និងវៀតណាមសម្រេចបានលើការងារព្រំដែន** ជាផែនទីផលិតឡើងតាមរយៈការថតរូបភាពពីលើអាកាស (orthophoto-maps) តាមបែបបច្ចេកវិទ្យាថ្មីទំនើប មានភាពជាក់លាស់ ដែលបង្ហាញយ៉ាងច្បាស់នូវទីតាំងបង្គោលព្រំដែន និងខ្សែព្រំដែន ដែលមានទាំងនិយាមកា និងឋានលេខាជាក់លាក់។

៥-**ដើម្បីងាយស្រួលក្នុងការទុកដាក់ និងប្រើប្រាស់ផែនទី**ឲ្យបានត្រឹមត្រូវ គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកនៃប្រទេសទាំងពីរ បានឯកភាពគ្នា**ចងក្រងផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ នេះ ជាសៀវភៅ** (album) **ផែនទីព្រំដែនតាមលក្ខណៈបច្ចេកទេស** ដើម្បីទុកប្រើប្រាស់ក្នុងប្រទេសរៀងៗខ្លួនតទៅ។

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមអំពាវនាវដល់ជនរួមជាតិទាំងក្នុង និងក្រៅប្រទេស សូមកុំជឿ និងកុំចែកចាយរាល់ការបង្ហោះសេចក្តីថ្លែងការណ៍បោកប្រាស់ខុសពីការពិតរបស់ក្រុមឧទ្ទាមក្រៅច្បាប់

និងគូកន ដែលតែងតែបង្កើតព័ត៌មានក្លែងក្លាយក្នុងចេតនាទុច្ចរិត ដើម្បីវាយប្រហារដល់កិច្ចការព្រំដែនរបស់រាជ-រដ្ឋាភិបាល ហើយដែលសកម្មភាពទាំងអស់នោះអាចប្រឈមមុខនឹងផ្លូវច្បាប់។

**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន** សូមបញ្ជាក់ជូនជាថ្មីថា ក្នុងកិច្ចការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា **ធ្វើឡើងយ៉ាងហ្មត់ចត់ ច្បាស់លាស់ តាមគោលការណ៍ខ្សែព្រំដែនមិនកែប្រែក្រោយកម្ពុជាបានឯករាជ្យ ស្របតាមផែនទីផ្លូវការ ខ្នាត ១/១០០ ០០០** ហើយដែលរហូតមកដល់បច្ចុប្បន្ននេះ សម្រេចបានលទ្ធផល៨៤% នៃខ្សែព្រំដែនរួម និងកំពុងបន្តធ្វើឱ្យបានចប់ជាស្ថាពរ១០០% ដើម្បីធានាបាននូវផ្ទៃក្រឡាដី ១៨១ ០៣៥ គីឡូម៉ែត្រការ៉េ រក្សាបាននូវបូរណភាពទឹកដី **និងអធិបតេយ្យភាពជាតិ មិនឲ្យជាតិ និងប្រជាជនខាតបង់ឡើយ**។

ថ្ងៃ១១រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២០
**គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន**